# បដិមាព្រះរាមរកឃើញនៅប្រាសាទចិន

ព្រះរាម គឺជាអវតារដ៏សំខាន់មួយក្នុងចំណោមអវតារសំខាន់ៗទាំង១០របស់ព្រះវិស្ណុ។ តួអង្គ ព្រះរាម គឺនិយាយនៅក្នុងរឿងរាមាយណដែលមានកត់ត្រានៅគម្ពីរបុរាណជាច្រើនក្នុងលទ្ធិវៃស្នវនិយម។ រឿងរាមាយណដ៏ល្បីល្បាញនៅស្រុកឥណ្ឌានេះ បានហូរចូលក្នុងសង្គមខ្មែរតាំងពីសម័យ មុនអង្គរមកម្ល៉េះ តួយ៉ាងដូចមាននិយាយនៅក្នុងសិលាចារឹកវាលកន្ទេល K.359 (ស.វ.ទី៧) និង មានភស្តុតាងជាចម្លាក់ឥដ្ឋនៅក្រុមប្រាសាទយាយព័ន្ធ នៃតំបន់ប្រាសាទសំបូរព្រៃគុកជាដើម។ ដោយឡែក ចំពោះបដិមាព្រះរាមវិញ គេប្រទះឃើញតែពីររូបប៉ុណ្ណោះនៅក្នុងសិល្បៈខ្មែរនាសម័យ បុរាណ ដែលបដិមាមួយរកឃើញនៅលើភ្នំដា ស្រុកអង្គរបុរី ខេត្តតាកែវ និងបដិមាមួយទៀតរកឃើញនៅប្រាសាទចិន តំបន់ប្រាសាទកោះកេរ ខេត្តព្រះវិហារ។ នៅក្នុងអត្ថបទនេះ យើងនឹង បង្ហាញអំពីបដិមាព្រះរាមចំនួន ១ រកឃើញនៅប្រាសាទចិន ដែលជាសិល្បៈរចនាបថកោះកេរ នា សតវត្សរ៍១០នៃគ្រឹស្តសករាជ។ តើបដិមាព្រះរាមនេះមានប្រវត្តិ និងលក្ខណៈបែបណាខ្លះ?

បដិមាព្រះរាមនេះ តម្កល់នៅតួប៉មខ្លោងទ្វារខាងកើតនៃប្រាសាទចិន។ បដិមានេះទៀតសោត សិល្បករបុរាណបានតម្កល់ឱ្យនៅជាក្រុមជាមួយបដិមាផ្សេងទៀត ដែលជាតួអង្គសំខាន់ៗនៅក្នុង រឿងរាមាយណ ដូចជា ព្រះលក្ស្មណ៍ ហនុមាន វាលី និងសុគ្រីព។ ពោល គឺផ្ទុយនឹងខ្លោងទ្វារខាងលិចដែលគេតម្កល់បដិមាចំនួន ៩ អង្គ ដែលសុទ្ធសឹងជាតួអង្គសំខាន់ៗនៅក្នុងរឿងមហាភារត។ ចំណែក តួប៉មកណ្តាលរបស់ប្រាសាទតម្កល់បដិមាព្រះវិស្ណុ ក្នុងរូបភាពជាទេពដែលមានព្រះនាម ថា "ស្រីបតី" (យោងសិលាចារឹក K.182)។ នៅក្នុងឆ្នាំ១៩៧២ ជនទុច្ចរិតបានលួចបដិមាព្រះរាម នេះ និងបដិមាមួយចំនួនទៀតចេញពីទីតាំងដើម ដើម្បីលក់ចេញទៅកាន់ឈ្មួញនៅបរទេស។ នៅ មុនឆ្នាំ១៩៨៦ បដិមាព្រះរាមមកពីប្រាសាទចិន បានដាក់តាំងបង្ហាញនៅក្នុងវិចិត្រសាលមួយ កន្លែងដែលមានឈ្មោះថា "Doris Weiner Gallery" ដែលមានទីតាំងស្ថិតនៅទីក្រុងញូវយ៉ក សហរដ្ឋអាមេរិច។ មកដល់ឆ្នាំ១៩៨៦ បដិមានេះគេបានលក់ចេញទៅឱ្យសារមន្ទីរមួយនៅក្នុងរដ្ឋកូឡូរ៉ាដូ សហរដ្ឋអាមេរិច ដែលមានឈ្មោះថាសារមន្ទីរ "Denver Art Museum"។ ជាង៣០ឆ្នាំក្រោយមក នៅក្នុងឆ្នាំ២០១៦ ក្រុមការងារសារមន្ទីរ Denver Art Museum ក៏បានសម្រេចប្រគល់បដិមានេះត្រឡប់មកកម្ពុជាវិញ ក្រោយពីមានការសិក្សាស្រាវជ្រាវរកប្រភពដើមយ៉ាងជាក់លាក់។ ការប្រគល់ បដិមានេះមកវិញ គឺមានតែត្រឹមដងខ្លួនចុះមកក្រោមប៉ុណ្ណោះ ដោយព្រះសិរបានបាត់បង់ទៅហើយ។ ចំណែកឯ ធ្នូ និងជើងទម្រភ្ជាប់ជាមួយកជើង គេបានរកឃើញនៅទីតាំងដើម។ ដូច្នេះហើយ

អត្ថបទដោយ៖ ម៉ង់ រ៉ាលី

អ្នកជំនាញនៅសារមន្ទីរជាតិកម្ពុជា បានជួសជុលភ្ជាប់ជើង និងដូជាមួយទេវរូប ដើម្បីយកដាក់តាំងបង្ហាញនៅក្នុងវិចិត្រសាលរបស់សារមន្ទីរ។

គួរកត់សម្គាល់ថា បដិមានេះក៏មិនខុសពីបដិមាផ្សេងទៀតដែលរកឃើញនៅប្រាសាទចិនដែរ ពោល គឺសិល្បករសាងឡើងអំពីថ្មភក់មួយដុំធំភ្ជាប់គ្នាជាមួយជើងទម្រ ហើយបដិមាគឺមានទំហំធំ និងកម្ពស់ខ្ពស់ (ប្រវែងកម្ពស់ដែលនៅសល់ មិនគិតជើងទម្រ គឺ ១,៦០ ម៉ែត្រ)។ បដិមានេះសាងឡើងក្នុងទម្រង់ឈរដោយមានជំហរត្រង់ ព្រះហស្តឆ្វេងកាន់ដងធ្នូ (ព្រះហស្តឆ្វេងនេះបាក់បែក និងបាត់បង់ទៅហើយ) រីឯព្រះហស្តស្តាំមិនដឹងថាកាន់អ្វីនោះឡើយ ហើយបាក់ត្រឹមកែងដៃ។ នៅលើដងខ្លួនទេវរូបនេះ យើងឃើញមានលម្អដោយក្បាច់ផ្សេងៗក្នុងទម្រង់ជាគ្រឿងអលង្ការ។ នៅផ្នែកខាងខ្នងបដិមា សិល្បករឆ្លាក់ជាបំពង់ដាក់គ្រាប់ព្រួញភ្ជាប់មកជាមួយ។ ចំណែកឯសំពត់បដិមាព្រះរាមនេះវិញ គឺមានទម្រង់ដូចទៅនឹងបដិមាផ្សេងៗទៀតនៅក្នុងរចនាបថកោះកេរដែរ ពោល គឺសំពត់ខ្លីមានគ្នីច្រើន មានជាយធំមួយទម្លាក់មកបាំងខ្សែក្រវ៉ាត់ចង្កេះផ្នែកខាងមុខ និងមានជាយពីរជាន់ធ្លាក់មករាងដូចកន្ទុយត្រីដែលខាងក្នុងវែងជាងខាងក្រៅ។ ការទម្លាក់ជាយពីរជាន់រាងដូចកន្ទុយត្រីបែបនេះ គេធ្លាប់ឃើញមាននៅក្នុងរចនាបថបាខែង នាស.វ.ទី៩ ដែរ ប៉ុន្តែខុសគ្នាត្រង់ថា នៅរចនាបថបាខែងជាយខាងក្រៅវែងជាងជាយខាងក្នុង។

បដិមាព្រះរាមដែលរកឃើញនៅប្រាសាទចិននេះ មើលទៅមានលក្ខណៈខុសពីបដិមាព្រះរាមដែលគេរកឃើញនៅរចនាបថភ្នំដាជាច្រើនចំណុចគួរកត់សម្គាល់។ ជាពិសេស គឺនៅត្រង់ថាបដិមាព្រះរាមរចនាបថភ្នំដាមានកាច់ចង្កេះខ្លាំង (សំស្ក្រឹតហៅថា "ភង្គ") ប៉ុន្តែបដិមាព្រះរាមនៅប្រាសាទចិនដែលស្ថិតនៅក្នុងរចនាបថកោះកេរមានជំហរត្រង់។ ម្យ៉ាងវិញទៀត ជើងទម្រ ដងខ្លួន និងសំពត់ក៏មិនដូចគ្នាដែរ។ លើសពីនេះ ប្រសិនបើមើលទៅលើទំហំខ្លួនបដិមាក៏កាន់តែខុសគ្នាឆ្ងាយ ដ្បិតជាទូទៅសិល្បៈនៅរចនាបថកោះកេរច្រើនតែផលិតឡើងដោយមានទំហំធំៗ។

ជារួមមក បដិមាព្រះរាមដែលរកឃើញនៅប្រាសាទចិន (តំបន់កោះកេរ) អាចចាត់ទុកថាគឺជាសិល្បៈដ៏កម្រមួយ ហើយមានលក្ខណៈល្អឯក។ ដ្បិត ចម្លាក់ដែលទាក់ទងនឹងព្រះរាមមានច្រើនណាស់ ប៉ុន្តែបដិមាព្រះរាមវិញ គឺមានតែពីរប៉ុណ្ណោះនៅក្នុងសិល្បៈខ្មែរ។ លក្ខណៈជាទូទៅគឺមិនសូវខុសគ្នាប៉ុន្មានពីបដិមាផ្សេងៗទៀតដែលរកឃើញនៅប្រាសាទចិននោះទេ។ អ្វីដែលគួរឱ្យត្រេកអរបំផុតនោះគឺ បដិមាអង្គនេះបានធ្វើមាតុភូមិនិវត្តន៍មកកាន់ប្រទេសកំណើតវិញកាលពីឆ្នាំ ២០១៦។

អត្ថបទដោយ៖ ម៉ង់ វ៉ាលី

## ឯកសារពិគ្រោះ

Boisselier, J. 1966. *Asie du Sud-Est, Le Cambodge*, Tome I, Paris.

Bourdonneau, E. 2014. 'Sculped Groups of the Eastern Gopura I in Prasat Chen (Koh Ker, Cambodia) and Khmer Art Collections of American Museum: *The Duel between Valin and Sugriva & The Fight between Narasimha and Hiranyakasipu.* A preliminary report" (September 2014, in collaboration with EFEO and APSARA).

Coral Rémusat, G. 1940*. L'Art Khmer, Les grandes étapes et son evolution, les éditions d'art et d'histoire*, Paris.

Dalsheimer, N. & Dagens, B. 2001, *Les collections du musée national de Phnom Penh, L'art du Cambodge ancient,* EFEO, Paris.

Dowling, N. 1999. 'A new date for the Phnom Da images and its implications for early Cambodia'. *Asian Perspectives* 38 (1): 51-61.

Mauger, H. 1936. L'Àsram Mahà Rosei. in: *BEFEO*. Tome 36, pp. 65-95.

Roveda, V. 2005, *Image of the gods,* River Book, Bangkok.

Swart, P. 2018. *Celebrating Khmer Cultural Heritage: Archaeology, Research and Restitution to Cambodia*,



រូបលេខ១៖ បដិមាព្រះរាមរកឃើញនៅប្រាសាទចិន ស.វ.ទី១០ (សព្វថ្ងៃនៅសារមន្ទីរជាតិកម្ពុជា)

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



រូបលេខ២៤៖ បដិមាព្រះរាមរកឃើញនៅប្រាសាទចិន ស.វ.ទី១០ (សព្វថ្ងៃនៅសារមន្ទីរជាតិកម្ពុជា)

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



រូបលេខ២៣៖ បដិមាព្រះរាមរកឃើញនៅប្រាសាទចិន ស.វ.ទី១០ (សព្វថ្ងៃនៅសារមន្ទីរជាតិកម្ពុជា)

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



រូបលេខ៤៖ បដិមាព្រះរាមរកឃើញនៅភ្នំដា ស.វ.ទី៦ (សព្វថ្ងៃនៅសារមន្ទីរជាតិកម្ពុជា)

អត្ថបទដោយ៖ ម៉ង់ រ៉ាលី